នស/រកត/០៨០១/២៨៩

# ព្រះរាជក្រឹត្យ

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

---

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : បង្កើត "ក្រុមប្រឹក្សាកីឡាកម្ពុជា" ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២ : ក្រុមប្រឹក្សាកីឡាកម្ពុជា មានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា | ប្រធាន |
| ២- ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកអចិន្ត្រៃយ៍ |
| ៤- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងការពារជាតិ | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក/. |

៩-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា — សមាជិក

១០-រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន — សមាជិក

១១-រដ្ឋមន្ត្រីក្រសួងសុខាភិបាល — សមាជិក

១២-រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ — សមាជិក

១៣-រដ្ឋមន្ត្រីក្រសួងបរិស្ថាន — សមាជិក

១៤-ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា — សមាជិក

១៥-ប្រធានគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា — សមាជិក

១៦-អគ្គនាយក នៃអគ្គនាយកដ្ឋានយុវជន និងកីឡា — សមាជិក

១៧-ប្រធានគ្រប់សហព័ន្ធកីឡាជាតិ — សមាជិក

មាត្រា ៣ : ភារកិច្ច និងសិទ្ធិរបស់ក្រុមប្រឹក្សាកីឡាកម្ពុជា :

- ក្រុមប្រឹក្សាកីឡាកម្ពុជា មានភារកិច្ចសម្របសម្រួល ណែនាំ ជួយជំរុញឧបត្ថម្ភ និងលើកស្ទួយវិស័យកីឡាជារួម និងវិស័យកីឡានិមួយៗ នៃព្រះរាជាណាចក្រកម្ពុជា
- ក្រុមប្រឹក្សាកីឡាកម្ពុជា មានសិទ្ធិបង្កើតក្រុមប្រឹក្សាកីឡាខេត្ត-ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា
- ក្រុមប្រឹក្សាកីឡាកម្ពុជា មានសិទ្ធិប្រើប្រាស់ថវិកា និងត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- សមាជិកក្រុមប្រឹក្សាកីឡាកម្ពុជា ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន
- ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវធ្វើជាសេនាធិការផ្ទាល់អោយក្រុមប្រឹក្សាកីឡាកម្ពុជា ។

មាត្រា ៤ : នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច ព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ល។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ១៩៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ សីហា ឆ្នាំ ២០០១

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ ៧ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ-ម៉ាន